សេចក្តីថ្លែងការណ៍ពីគោលជំហររបស់អង្គការ
ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល

ខែសីហា ឆ្នាំ២០១៧

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

# ការធ្វើឱ្យប្រសើរឡើងនូវការអប់រំបរិយាប័ន្នសម្រាប់កុមារពិការនៅកម្ពុជា

## សាវតា

ក្រសួងអប់រំ យុវជននិងកីឡានៅប្រទេសកម្ពុជា ដៃគូអភិវឌ្ឍន៍នានា និងរដ្ឋាភិបាលនៅទូទាំងពិភពលោកកំពុងរៀបចំផែនការ និងអនុវត្តជំហានឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅត្រឹមឆ្នាំ២០៣០។ គោលដៅទី៤ មានគោលបំណងធានាឱ្យបាននូវការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា នៅត្រឹមឆ្នាំ២០៣០។ ចំណុចដៅទី៥ នៃគោលដៅនេះគឺ *"លុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាឱ្យបានភាពស្មើគ្នាក្នុងការចូលរៀនគ្រប់កម្រិតទាំងអស់នៃការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនងាយរងគ្រោះ រួមទាំងជនពិការ ជនជាតិដើមភាគតិច និងកុមារក្នុងស្ថានភាពងាយរងគ្រោះ"*។

វឌ្ឍនភាពមួយចំនួន ត្រូវបានកត់សម្គាល់នៅក្នុងវិស័យអប់រំបរិយាប័ន្ននៅប្រទេសកម្ពុជាដោយផ្តោតលើកុមារពិការ។ច្បាប់និងគោលនយោបាយជាតិជាច្រើនត្រូវបានអនុម័ត ដើម្បីធានាសិទ្ធិអប់រំសម្រាប់កុមារ /ជនពិការ និងលើកកម្ពស់ការអប់រំបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា។ សមិទ្ធផលថ្មីៗរបស់ក្រសួងអប់រំ យុវជននិងកីឡានៅប្រទេសកម្ពុជារួមមាន៖ ការបង្កើតនាយកដ្ឋានអប់រំពិសេសនៅឆ្នាំ២០១៦ ដើម្បីធានាឱ្យមានការអនុវត្តគោលនយោបាយនានានិងការអនុម័តនាពេលថ្មីៗនេះស្តីពីការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស។

សង្គមស៊ីវិលទទួលស្គាល់ និងសូមអបអរសាទរចំពោះវឌ្ឍនភាពវិជ្ជមាននេះក្នុងវិស័យអប់រំបរិយាប័ន្ន ដែលដឹកនាំដោយក្រសួងអប់រំយុវជននិងកីឡា។ ទោះជាយ៉ាងនេះក៏ដោយ បញ្ហាប្រឈមនៅតែមាន ហើយទាមទារឱ្យមានការដោះស្រាយដោយក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ។ បញ្ហាប្រឈមទាំងនេះត្រូវបានរកឃើញនៅក្នុងវេទិកាជាតិលើកទី៥ ស្តីពីការអប់រំបរិយាប័ន្ន។

ព្រឹត្តិការណ៍ប្រចាំឆ្នាំនេះត្រូវបានរៀបចំឡើងនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦។ អ្នកចូលរួមជាង១៧០នាក់ មកពីស្ថាប័នពាក់ព័ន្ធផ្សេងៗ (ប្រធានមន្ទីរអប់រំ តំណាងអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ មន្ត្រីពាក់ព័ន្ធមកពីក្រសួងអប់រំយុវជន និងកីឡា និងតំណាងជនពិការ) បានកំណត់បញ្ហាប្រឈមចំនួន៤សំខាន់ៗ គឺការបណ្តុះបណ្តាលគ្រូបង្រៀន ការគ្រប់គ្រងសាលារៀន ការកំណត់អត្តសញ្ញាណ និងការត្រួតពិនិត្យ និងតាមដាន។ បញ្ហាប្រឈមបន្ថែមទៀត ត្រូវបានកំណត់នៅក្នុងរបាយការណ៍បន្ទាប់រួមមាន "ខ្វះការបណ្តុះបណ្តាលសមត្ថភាព ជំនាញបច្ចេកទេស ចំណេះដឹង និងការយល់ដឹងពីពិការភាព" ។

ការស្រាវជ្រាវកំរិតសហគមន៍ឆ្នាំ២០១៤ របស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ដែលមានឈ្មោះថា "សិទ្ធទទួលបានការអប់រំនៅប្រទេសកម្ពុជា" បានលើកឡើងថាលទ្ធភាពទទួលបានការសិក្សា សម្រាប់កុមារជនជាតិភាគតិច កុមារពិការ និងកុមារនៅក្នុងគ្រួសារក្រីក្រ នៅមានកម្រិត។

របកគំហើញសំខាន់ៗ នៃបទបង្ហាញរបស់អង្គការយូនីសេហ្វ ធ្វើឡើងនៅថ្ងៃទី១៤ ខែមិថុនាឆ្នាំ ២០១៧ បញ្ជាក់ថាការរើសអើងកុមារពិការនៅតែជាបញ្ហា ហើយសកម្មភាពតស៊ូមតិមិនទាន់បានអនុវត្តនៅក្នុងគ្រប់វិស័យនិងគ្រប់កម្រិតនៃរដ្ឋាភិបាលទេ។ ឧទាហរណ៍ការកំណត់អទិភាពកុមារពិការ គឺជាបញ្ហាប្រឈមនៅក្នុងផែនការវិនិយោគឃុំ ដោយសារការខ្វះធនធាន (ធនធានមនុស្ស ធនធានបច្ចេកទេស និងហិរញ្ញវត្ថុ)។ លើសពីនេះទៅទៀតជនពិការនិងគ្រួសាររបស់ពួកគេក៏អាចជួបប្រទះភាពក្រីក្រផងដែរ។

ការដោះស្រាយបញ្ហាដែលនៅសេសសល់ និងឧបសគ្គចំពោះការអប់រំបរិយាប័ន្ន និងការធានាឱ្យបានថាកុមារពិការមកពីសហគមន៍ទាំងអស់ទទួលបាននូវការអប់រំប្រកបដោយគុណភាព តម្រូវឱ្យដៃគូទាំងអស់ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា រួបរួមគ្នា៖

## អនុសាសន៍

១៖ ប្រមូលផ្តុំការអនុវត្តនានាទាក់ទងនឹងការអប់រំបរិយាប័ន្ននៅគ្រប់កម្រិត និងគ្រប់វិស័យអប់រំ ជាពិសេសផ្តោតទៅលើការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការបណ្តុះបណ្តាលគ្រូបង្រៀន។

២៖ ពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដែលពាក់ព័ន្ធនឹងការអប់រំពិសេស។

៣៖ វិនិយោគលើការធ្វើឱ្យប្រសើរឡើងនូវការតាមដានការគ្រប់គ្រងសាលារៀន ដែលពាក់ព័ន្ធនឹងការអប់រំពិសេស។

## គោលជំហររបស់យើង

**អនុសាសន៍ទី១៖** ប្រមូលផ្តុំការអនុវត្តន៍នានាទាក់ទងនឹងការអប់រំបរិយាប័ន្ននៅគ្រប់កម្រិតនិងគ្រប់វិស័យអប់រំជាពិសេសផ្តោតទៅលើការអប់រំកុមារតូចការអប់រំបឋមសិក្សានិងការបណ្តុះបណ្តាលគ្រូបង្រៀន។

ចាប់តាំងពីឆ្នាំ២០១២ការបណ្តុះបណ្តាលបឋមសម្រាប់គ្រូមានចំនួន២៨ ម៉ោង ផ្តោតលើការអប់រំពិសេស។ ចំនួនម៉ោងនេះគឺគ្រាន់តែជាផ្នែកតូចមួយ នៃរយៈពេលនៃការបណ្តុះបណ្តាលដែលចាំបាច់សម្រាប់គ្រូ ដើម្បីឱ្យមានសមត្ថភាពបង្រៀនកុមារពិការ។ លោកគ្រូ អ្នកគ្រូដែលបានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្រៀនមុនកាលបរិច្ឆេទនេះ មិនបានទទួលការបណ្តុះបណ្តាលណាមួយទាក់ទងនឹងការអប់រំពិសេសទេ។ របាយការណ៍ឆ្នាំ២០១៦ ចេញដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ស្តីពីកម្មវិធីអន្តរាគមន៍របស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយកុមារពិការ បានបង្ហាញថាអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៤ លើកឡើងថា "កង្វះការបណ្តុះបណ្តាលសមត្ថភាព និងជំនាញបច្ចេកទេសក្នុងការធ្វើការជាមួយកុមារពិការ" គឺជាបញ្ហាប្រឈមដ៏ធំមួយ។

ចំនួនម៉ោងនៃការបណ្តុះបណ្តាលគួរតែបង្កើនឡើង តាមរយៈការធ្វើការជិតស្និទ្ធ រវាងនាយកដ្ឋានបណ្តុះបណ្តាលគ្រូបង្រៀន នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សានិងនាយកដ្ឋានអប់រំពិសេស។

កង្វះខាតសម្ភារៈ និងធនធានត្រូវបានគេទទួលស្គាល់នៅក្នុងផ្នែកផ្សេងៗនៃវិស័យអប់រំ ហើយកង្វះខាតសម្ភារៈសិក្សាដែលសមស្របសម្រាប់កុមារពិការ ត្រូវបានរកឃើញតាមរយៈរបាយការណ៍ឆ្នាំ២០១៦ របស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល។

តាមរយៈការកៀគរអ្នកប្រឹក្សាបច្ចេកទេសបន្ថែមទៀត ដើម្បីសហការជាមួយនាយកដ្ឋានបណ្តុះបណ្តាល និងនាយកដ្ឋានអប់រំពិសេស ផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោលក្នុងការតាមដាន/កំណត់អត្តសញ្ញាណកុមារពិការ និងធ្វើឱ្យសម្ភារៈបង្រៀនសម្រាប់ការអប់រំបរិយាប័ន្ន មាននៅគ្រប់មជ្ឈមណ្ឌលគរុកោសល្យ បង្កើនលទ្ធភាពទទួលបានជំនាញឯកទេស និងឯកសារសម្រាប់ការបណ្តុះបណ្តាលអប់រំបរិយាប័ន្ន។

របាយការណ៍ឆ្នាំ២០១៦ ចេញដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ស្តីពីកម្មវិធីអន្តរាគមន៍របស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការជាមួយកុមារពិការ ក៏បញ្ជាក់ផងដែរថាកង្វះចំណេះដឹង និងការយល់ដឹងអំពីពិការភាព និងកង្វះការគាំទ្រពីឪពុកម្តាយដើម្បីលើកទឹកចិត្តកូនៗ របស់ពួកគេឱ្យទទួលបានការអប់រំគឺជាបញ្ហាប្រឈមមួយទៀត។ ដូច្នេះ ជាការចាំបាច់ដែលក្រសួងអប់រំ គួរតែលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការរកឃើញដំបូង និងការធ្វើអន្តរាគមន៍ឆាប់រហ័សជាមួយមាតាបិតា សហគមន៍ គ្រូបង្រៀន នាយកសាលា និងអ្នកពាក់ព័ន្ធដទៃទៀត។ ការលើកកម្ពស់ការយល់ដឹងអំពីការអប់រំបរិយាប័ន្នសម្រាប់កុមារពិការ ត្រូវតែធ្វើឡើងជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ/មូលដ្ឋាន ដូចជាមន្ទីរអប់រំខេត្តនិងការិយាល័យអប់រំស្រុក។

**អនុសាសន៍ទី២៖** ពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដែលធ្វើការពាក់ព័ន្ធនឹងការអប់រំពិសេស

បើមិនមានកិច្ចសហប្រតិបត្តិការដ៏រឹងមាំ រវាងក្រសួងពាក់ព័ន្ធទេនោះ នឹងមិនមានប្រព័ន្ធប្រកបដោយនិរន្តរភាពសម្រាប់បញ្ជូន

សិស្សពិការឱ្យទទួលបានសេវាអប់រំពិសេសដែលសមស្របនោះឡើយ។ ដូ ច្នេះយើងស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាកំណត់ក្របខ័ណ្ឌច្បាស់ លា ស់មួយ ហើយរៀបចំ (ឬផ្សព្វផ្សាយ) ឯកសារច្បាប់នា នា ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងក្រសួងស្ថាប័នពាក់ព័ន្ធ និងដាក់ទៅថ្នាក់ក្រោមជាតិដើម្បីអនុវត្ត។

យើង ក៏លើកទឹកចិត្តដល់រាជរដ្ឋាភិបាល ក្នុងការបង្កើតគោលនយោបាយច្បាស់លាស់មួយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់នាយកដ្ឋានអប់រំពិសេស ក៏ដូចជាដើម្បីធ្វើបច្ចុប្បន្នភាព និងបង្កើតផែនការមេដើម្បីអនុវត្តគោលនយោបាយអប់រំសម្រាប់កុមារពិការ។ នៅក្នុងបរិបទនេះ ការធ្វើការតំរង់ទិសយ៉ាងស៊ីជំរៅលើគោលនយោបាយទាំងនេះ ត្រូវតែផ្តល់ឱ្យភាគីពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**អនុសាសន៍ទី៣:** វិនិយោគលើការធ្វើឱ្យប្រសើរឡើងនូវការតាមដានការគ្រប់គ្រងសាលារៀន ដែលពាក់ព័ន្ធនឹងការអប់រំពិសេស

ដើម្បីឱ្យរាជរដ្ឋាភិបាល និងសាលារៀនមានលទ្ធភាពកែតម្រូវឆ្លើយតបនូវតម្រូវការ និងការរំពឹងទុក ដែលតែងតែផ្លាស់ប្តូររបស់អ្នកពាក់ព័ន្ធទាំងអស់ គួរតែមានប្រព័ន្ធតាមដាន និងវាយតម្លៃសាលារៀនមួយដែលមានប្រសិទ្ធិភាព និងដំណើរការល្អ។ យើងសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យបង្កើតប្រព័ន្ធមានបុគ្គលម្នាក់ទទួលបានការបណ្តុះបណ្តាលជាក់លាក់ ក្នុងការអប់រំពិសេសនៅគ្រប់កម្រិតនៃការអប់រំៈ នាយកសាលា ក្រុមការងារបណ្តុះបណ្តាល និងតាមដានថ្នាក់ស្រុក សាលាការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងនាយកដ្ឋានអប់រំពិសេស ដើម្បីតាមដានការអប់រំកុមារពិការ។ នៅពេលបុគ្គលម្នាក់ៗទទួលបានការបណ្តុះបណ្តាលពិសេសលើការអប់រំពិសេស ក្រុមការងារដើម្បីតាមដានការអនុវត្ត គួរតែត្រូវបានបង្កើតឡើងនៅគ្រប់សាលារៀនទាំងអស់ ហើយតំណាងឪពុកម្តាយសិស្សម្នាក់ គួរតែត្រូវបានចាត់តាំងឱ្យចូលរួមសង្កេតការណ៍ក្នុងក្រុមការងារនេះ។

លើសពីនេះទៀត យើងសូមឱ្យមានការចែករំលែកការបង្រៀនល្អៗ តាមរយៈការបង្ហាញ វីដេអូ និងសម្ភារៈថ្មីៗនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់សាលាកម្រង។

ចុងបញ្ចប់ ថវិកាជាក់លាក់ និងសកម្មភាពពាក់ព័ន្ធនឹងការអប់រំបរិយាប័ន្នសម្រាប់កុមារពិការ ត្រូវចាត់ជាអទិភាពនិងដាក់ចូលទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន។ការងារនេះត្រូវតាមដានដោយថ្នាក់ស្រុកនិងថ្នាក់ខេត្ត។

សកម្មភាពគាំទ្រដែលត្រូវបានណែនាំគឺ:

- កៀគរមាតាបិតាសិស្ស គណៈកម្មការទ្រទ្រង់សាលារៀន ក្រុមប្រឹក្សាឃុំ និងតំណាងសហគមន៍ដើម្បីតាមដាននៅថ្នាក់រៀនក្រៅផ្លូវការ តាមរយៈការប្រជុំទៀងទាត់ (យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ) ដោយយ៉ាងហោចណាស់អ្នកចូលរួមមាន 50% ជាមាតាបិតាសិស្ស។
- ធានាថារបាយការណ៍ធ្វើផែនទីសហគមន៍ និង/ឬ ការបង្កើតផែនទីសាលារៀន ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព ហើយព័ត៌មានទាក់ទងនឹងកុមារពិការដែលដល់អាយុសិក្សាត្រូវបានធ្វើបច្ចុប្បន្នភាពនៅតាមសាលារៀននីមួយៗជារៀងរាល់ឆ្នាំ។
- បង្កើតឱ្យមានប្រព័ន្ធប្រកបដោយនិរន្តរភាព និងស្តង់ដារសម្រាប់បញ្ជូនកុមារពិការ អោយទទួលបានសេវាសមស្របដើម្បីបង្កើនឱកាសអប់រំសម្រាប់ពួកគេ។
- បណ្តុះបណ្តាលនាយកសាលា លើការអនុវត្តការគ្រប់គ្រងដែលជាក់លាក់ទាក់ទងនឹងការអប់រំបរិយាប័ន្ន និងអប់រំពិសេស ហើយតាមដានពីថ្នាក់ស្រុក ចងក្រងការអនុវត្តល្អៗ ក្នុងការប្រជុំកម្រងប្រចាំខែ។

## សម្លេងពីអង្គការសង្គមស៊ីវិល

> "មានអាកប្បកិរិយានៃភាពរស់សឡឹមពីឪពុកម្តាយ និងគ្រូ និងកង្វះធនធានមនុស្ស ដែលបានទទួលការបណ្តុះបណ្តាល។"
>
> *សមាជិករបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការលើការអប់រំពិសេស*

> "យើងត្រូវការការប្តេជ្ញាចិត្តខ្ពស់ពីគ្រូបង្រៀន ដើម្បីរៀនសូត្រចំណេះដឹង និងជំនាញដើម្បីបង្រៀនកុមារពិការភ្នែកថ្នាក់។"
>
> *សមាជិករបស់អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការលើការអប់រំពិសេស*

## ឯកសារយោង និងឥស្សតាង:


1. សេចក្តីប្រកាសនៃទីក្រុងអ៊ីងឈន់ សាធារណរដ្ឋកូរ៉េ ឆ្នាំ២០១៥ ។
2. ព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ។ ភ្នំពេញ ប្រទេសកម្ពុជា ឆ្នាំ២០០៧ ។
3. ព្រះរាជាណាចក្រកម្ពុជា។ គោលនយោបាយសាលា កុមារមេត្រី ។ ភ្នំពេញ ប្រទេសកម្ពុជាឆ្នាំ២០០៧។
4. ព្រះរាជាណាចក្រកម្ពុជា។ គោលនយោបាយអប់រំសម្រាប់កុមារពិការ។ ភ្នំពេញ ប្រទេសកម្ពុជាឆ្នាំ២០០៨។
5. ព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ ភ្នំពេញ ប្រទេសកម្ពុជាឆ្នាំ២០០៩។
6. អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល។ សិទ្ធិទទួលបានការអប់រំនៅកម្ពុជា (ការស្រាវជ្រាវកំរិតសហគមន៍)។ ភ្នំពេញ ឆ្នាំ២០១៤ ។
7. អង្គការយូនីសេហ្វ Ms. Alexandra Devine, et al. បទបង្ហាញពីចំណុច នៃការរកឃើញបឋមស្តីពីការវិភាគស្ថានភាពកុមារពិការនៅកម្ពុជា។ ឆ្នាំ២០១៧ ។
8. អង្គការសហប្រជាជាតិ។ ការផ្លាស់ប្តូរពិភពលោករបស់យើង៖ របៀបវារៈ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ញូវយ៉ក សហរដ្ឋអាមេរិក ឆ្នាំ២០១៥ ។
9. អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល។ របាយ-ការណ៍ផែនទីរបស់អង្គការក្រៅរដ្ឋាភិបាល ធ្វើការងារអប់រំសម្រាប់កុមារពិការ។ ភ្នំពេញ ប្រទេសកម្ពុជាឆ្នាំ ២០១៦ ។



BMZ Bundesministerium für wirtschaftliche Zusammenarbeit und Entwicklung

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល NGO EDUCATION PARTNERSHIP

vhs DVV International

*គម្រោងនេះឧបត្ថម្ភថវិកាដោយសភាពអឺរ៉ុប និងសហឧបត្ថម្ភដោយ BMZ*

*គម្រោងនេះអនុវត្តដោយ អង្គការភាពដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល និង DVV អន្តរជាតិ*



*ទស្សនៈដែលបង្ហាញនៅក្នុងការបោះពុម្ពផ្សាយនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍អឺរ៉ុបទេ*